# ការសម្ភាសន៍របស់លោកយាយ តេង ផល

**កៈ អ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណនរិទ្ធ ខៈ អ្នកត្រូវគេសម្ភាសន៍ឈ្មោះ តេង ផល**

## ពត៌មានសង្ខេបរបស់លោកយាយតេង ផល

លោកយាយតេង ផលមានអាយុ៨៧ឆ្នាំហើយឆ្នាំនេះហើយគាត់ជាអ្នកខេត្តកណ្ដាលទេ តែគាត់បានផ្លាស់ប្ដូរមកតាំងទីលំនៅដ្ឋាននៅខេត្តសៀមរាបប្រហែលជា៣០ឆ្នាំហើយ។ គាត់មានបងប្អូនចំនួន៧នាក់ហើយគាត់ជាកូនទី២ក្នុងគ្រួសាររបស់គាត់។ គាត់បានបាត់ បង់កូនចំនួន២នាក់ក្នុងសម័យប៉ុល ពតដោយសារតែគាត់គ្មានអ្វីឲ្យកូនៗហូបៗ។

កៈ បាទជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់យាយដែលបានឲ្យខ្ញុំសម្ភាសន៍ពីប្រវិត្តរបស់យាយ ហើយការសម្ភាសន៍ណឹងត្រូវបានរៀបចំដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថាព្រីហាំយ៉ង់ដែលនៅឯសហរដ្ឋអាមេរិក។ បាទគោលបំណងរបស់សាកលវិទ្យាល័យគឺចង់សម្ភាសន៍ប្រវិត្តប្រជាជនខ្មែរ ដើម្បីរក្សារទុកប្រវិត្តប្រជាជនខ្មែរដើម្បីឲ្យកូនចៅជំនាន់ក្រោយរបស់ពួកគាត់អាចស្គាល់ពីប្រវិត្តរបស់ជីដូនជីតាហើយរៀនអំពីប្រវិត្តរបស់ពួកគាត់ណាយាយ បាទ ហើយចឹងនៅពេលដែលខ្ញុំសម្ភាសន៍យាយចប់ ខ្ញុំនឹងដាក់ការសម្ភាសន៍របស់យាយណឹងនៅក្នុងវេបសាយរបស់សាលាដែលមានឈ្មោះថា www.cambodiaoralhistory.byu.edu ណាយាយ ចឹងតើយាយយល់ព្រមឲ្យខ្ញុំដាក់សម្ភាសន៍របស់យាយចូលទៅក្នុងវេបសាយរបស់សាលាទេយាយ?

ខៈ មានអីដាក់ទៅ។

កៈ បាទចឹងសម្រាប់ថ្ងៃខែដែលខ្ញុំសម្ភាសន៍នេះគឺ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ ហើយការសម្ភាសន៍នេះត្រូវបានធ្វើឡើងនៅភូមិចុងឃ្នៀស សង្កាត់ចុងឃ្នៀស ស្រុកសៀមរាប ខេត្តសៀមរាប ហើយខ្ញុំជាអ្នកសម្ភាសន៍ឈ្មោះហេង សុវណ្ណនរិទ្ធ ចុះយាយមានឈ្មោះអ្វីដែរយាយ?

ខៈ ខ្ញុំឈ្មោះតេង ផល។

ក៖ ចុះយាយមានឈ្មោះហៅក្រៅទេយាយ?

ខ៖ អត់ទេ តែតេង ផល ចាស។

ក៖ ចុះឆ្នាំនេះយាយមានអាយុប៉ុន្មានហើយ?

ខ៖ ខ្ញុំអាយុចូល៨៧ឆ្នាំ។

ក៖ តើយាយចាំថាយាយកើតនៅថ្ងៃខែឆ្នាំកំណើតទេយាយ?

ខ៖ ខ្ញុំអត់ចាំទេវាភ្លេចអស់ហើយ ខ្ញុំភ្លេចអស់ហើយដឹងតែអាយុ៨៧ណឹង។

ក៖ ចុះឆ្នាំខ្មែរយាយចាំថាយាយកើតឆ្នាំណាទេ?

ខ៖ កាលនោះខ្ញុំចាំតែកាលនេះទៅខ្ញុំភ្លេចអស់ហើយខ្ញុំអត់ចាំ ដល់កើតមកឃើញតែមុខដំបូងតស្សូរ ឥស្សូរណឹងក៏រត់កាលណឹងនៅក្រមុំក៏គេរកចាប់កូនក្រមុំទៅឪពុកខ្ញុំក៏ធ្វើកន្ទេលរុំខ្មើយក៏ដាក់គៀនជង្រុកស្រូវទៅក៏ដកដង្ហើមតាមកន្ទេលណឹងទំរាំវាចេញផុត ចាសក៏ចេញផុតទៅក៏បានបាត់រួចមួយគ្រាទៅ ដល់រួចឆ្នាំក្រោយទៀតបានអាពត អាពតទៀតខ្ញុំបានប្តីដល់បានប្តីទៅក៏ការទៅរត់មួយសារទៀត។

ក៖ ចុះយាយមានស្រុកកំណើតនៅឯណាដែរយាយ?

ខ៖ ខ្ញុំនៅកំរែង ស្រុកកំរែង ខេត្តកណ្តាល

ក៖ ចុះយាយមានបងប្អូនចំនួនប៉ុន្មាននាក់ដែរយាយ?

ខ៖ កាលនោះបងប្អូនខ្ញុំមាន៧នាក់ ដល់ឥឡូវនេះអាពតសម្លាប់អស់ហើយនៅសល់តែប្អូនស្រីមួយកំពុងតែឈឺនៅភ្នំពេញ ចាសនៅស្រី២នាក់នោះឯង។

ក៖ យាយជាកូនទីប៉ុន្មានដែរយាយ?

ខ៖ ខ្ញុំកូនទី២ បងប្រុសខ្ញុំទី១គេសម្លាប់ចោលដែរសម្លាប់ទាំងអស់។

ក៖ ចឹងយាយអាចប្រាប់ឈ្មោះទាំងអស់របស់បងប្អូនយាយបានទេ?

ខ៖ បានទីមួយនោះឈ្មោះតេង ឃឹន បងប្រុសតេង ឃឹនមកបានខ្ញុំតេង ផល តេង ផលរួចទៅបានប្អូនស្រីនោះតេង ផាត តេង ផាតរួចទៅបានប្អូនទៀត តេង ឃួន តេង ឃួនរួចទៅបានតេង កាន តេង កានមួយទៀតទៅបានតេង អឿន តេង អឿនមួយទៀត ទៅក៏យើងប្អូនប្រុសពៅនោះ យឿន បងប្អូន៧នាក់។

ក៖ ប៉ុន្តែសព្វថ្ងៃនៅតែ១នាក់ទេ?

ខ៖ ចាស សព្វថ្ងៃនៅខ្ញុំហើយនិងប្អូននោះឯង ស្រី២នាក់ប្រុសៗគេសម្លាប់អស់ហើយ។

ក៖ ចុះយាយមានចាំសាច់រឿងអ្វីខ្លះជាមួយបងប្អូនរបស់យាយ តាំងពីក្មេងៗមកយាយ? ទាំងសាច់រឿងសប្បាយ ទាំងកម្សត់ដែលមានជាមួបងប្អូន យាយចាំទេ?

ខ៖ មានអីសប្បាយជាមួយបងប្អូនលេងសើចនោះឯងមានកើតទុក្ខអីអត់ទេ ស្រាប់តែដល់ឥស្សរណឹងទៅបែកគ្នាប្អូនទៅរៀនទៅសូត្រអីចឹងទៅក៏បែកគ្នាអស់ ដល់បែកគ្នាទៅមកដល់អាពតគេចាប់ប្អូនទៅអស់រលីងចាសប្អូនរៀនទៅប្អូនកំពុងតែរៀនគេយកទៅអស់ ហើយបងនោះធ្វើការក្រសួងសុរិយោដីនោះគេយកទៅដែរ យកទាំងប្ដីខ្ញុំយកទាំងប្អូនខ្ញុំ ប្ដីប្អូនខ្ញុំយកទៅអស់ចាសខ្ញុំនោះកូនខ្ចីដល់កូនខ្ចីទៅគេទុកកូននោះគេឲ្យនៅមើលកូន កូនពៅមួយនោះនៅសព្វថ្ងៃចាសគេឲ្យមើលកូនអត់ចល័តកម្សត់។

ក៖ យាយចូលចិត្តធ្វើអ្វីខ្លះដែរជាមួយបងប្អូនរបស់យាយឬក៏ចូលចិត្តលេងអ្វីដែរជាមួយពួកគាត់?

ខ៖ ជាមួយបងប្អូនខ្ញុំអត់មានលេងអីទេមានតែលេងបិទពួន។

ក៖ ចូលចិត្តលេងបិទពួន?

ខ៖ ចាសលេងបិទពួនលេងអីនោះឯង បបួលគ្នាលេងលាក់កន្សែង។

ក៖ ចឹងចង់សួរទាក់ទងនិងម្ដាយរបស់យាយវិញ តើគាត់មានឈ្មោះអ្វីដែរយាយ?

ខ៖ ម្ដាយឈ្មោះខៀវ តូច ឪពុកខ្ញុំមុំ តេង

ក៖ ចឹងយាយស្គាល់ថ្ងៃខែឆ្នាំកំណើតគាត់ទេ?

ខះ អត់ស្គាល់ទេ ពីដើមកត់មានមែនដល់ខ្ញុំអាពតវានេះទោវាយកអស់ហើយ វារើយកអីទៅវាដុតភ្លើង យកទៅដុតភ្លើងអស់ទៅបានភ្លេចកំណើតអស់ ចាសពីដើមមានឪពុកខ្ញុំកត់ថ្ងៃខែខ្ញុំកើតខែនេះគាត់កើតខែនោះអីមានគ្រប់ឲ្យកូនមើលទាំងអស់ ចាសវាយកទៅដុតអស់ក៏ភ្លេចអស់អត់មានចាំទេ។

កះ ចុះម្តាយរបស់យាយគាត់មានស្រុកកំណើតនៅឯណាដែរយាយ?

ខះ ម៉ែខ្ញុំក៏នៅកំរែងនោះដែរ ចាសខេត្តកណ្តាលណឹងឯងដែរម៉ែខ្ញុំក៏នៅណឹងឪខ្ញុំក៏នៅស្រុកណឹង។

កះ ចុះយាយមានចងចាំសាច់រឿងអ្វីខ្លះពីម្តាយរបស់យាយកាលពីនៅក្មេងៗ?

ខះ ម៉ែខ្ញុំនៅពីក្មេងគាត់មានអីគាត់ថាគាត់ភ្ជួរស្រែព្រោះបងប្រុសៗគេបានប្រពន្ធអស់ទៅម៉ែខ្ញុំកូនពៅគេភ្ជួររាស់អីចឹងទៅស្ទូង ដកអីប៉ុណ្ណឹងឯង។

កះ ចុះម្តាយរបស់យាយគាត់ជាមនុស្សបែបណាដែរយាយ? គាត់ស្លូត ឬក៏គាត់កាច?

ខះ ម៉ែខ្ញុំស្លូតទេឪពុកខ្ញុំក៏ស្លូតអត់មានកាចទេស្រលាញ់កូនស្រលាញ់ចៅសឹងអី កូនចៅអីមិនដែលវ៉ៃមិនដែលជេរទេ។

កះ ចុះម្តាយរបស់យាយគាត់ប្រកបមុខរបរអ្វីដែរដើម្បីចិញ្ចឹមជីវិតដែរយាយ?

ខះ ម្តាយខ្ញុំធ្វើតែស្រែចាសធ្វើតែស្រែយាយខ្ញុំក៏ធ្វើស្រែ រួចស្រែទៅក៏បបួលគ្នាមានអីក៏នៅផ្ទះទៅ លក់ស្រូវហូបទៅទិញត្រីទិញម្ហូបទៅ។

កះ ចឹងស្រុកកំណើតឪពុករបស់យាយក៏នៅ?

ខះ ចាសនៅកំរែងណឹងដែរ។

កះ ចុះឪពុករបស់យាយគាត់ជាមនុស្សស្លូតឬក៏កាចដែរ?

ខះ ឪពុកខ្ញុំស្លូត ប៉ុន្តែគាត់ឡើងត្នោតចឹងទៅឪពុកខ្ញុំឡើងត្នោតទៅម្តាយខ្ញុំទៅរែកទឹកត្នោតទទួលគាត់ធ្វើស្ករធ្វើអីទៅ។

កះ ចុះយាយចាំសាច់រឿងអ្វីបំផុតជាងគេដែរពីឪពុកម្តាយរបស់យាយ?

ខ៖ មានអីដឹងតែឪពុកក៏យើងឡើងត្នោតប៉ុណ្ណោះឯងហើយនិងធ្វើស្កររធ្វើអីណឹងឯង។

ក៖ ចុះឪពុករបស់យាយគាត់ប្រកមមុខរបរអ្វីដែរ? គាត់ឡើងត្នោតហើយនិងធ្វើស្រែ?

ខ៖ ចាសធ្វើតែប៉ុណ្ណោះឯងអត់មានអីទេ។

ក៖ ចុះឪពុករបស់យាយគាត់ធ្លាប់ប្រាប់សាច់រឿងរបស់គាត់កាលពីក្មេងមកកាន់យាយទេ?

ខ៖ អត់ទេ អត់មាននិយាយអីទេ អត់ដែលនិយាយប្រាប់កូនប្រាប់ចៅអីទេ ដឹងតែកូន សុខសប្បាយទៅលេងបងប្អូនទៅសុខសប្បាយទៅអត់មានប្រាប់រឿងរ៉ាវអីទេ អាងតែគាត់ទុកឲ្យកូនហើយមានអស់ហើយទុកគ្រាន់ឲ្យកូនមើលតែអាពតវាដុតចោលអស់។

ក៖ ចុះយាយខាងម្តាយរបស់យាយគាត់មានឈ្មោះអ្វីដែរយាយ?

ខ៖ យាយម៉ែខ្ញុំឈ្មោះអ៊ុច ប្តីគាត់ឈ្មោះខៀវ  អ៊ុច ខៀវ យាយឈ្មោះអ៊ុច តាឈ្មោះ ខៀវ។

ក៖ ចឹងយាយមានចាំឆ្នាំកំណើតគាត់ទេ?

ខ៖ អត់ទេមិនដែលចាំទេ។

ក៖ ចឹងយាយចាំថាពួកគាត់មានស្រុកកំណើតនៅកន្លែងណាដែរយាយ?

ខ៖ យាយខ្ញុំក៏នៅស្រុកណឹងដែរនៅស្រុកណឹងឯង តាក៏នៅនោះឯងនៅស្រុកណឹងឯដូចតែគ្នាមានពីណាមកទេ។

ក៖ ចុះយាយចាំសាច់រឿងអ្វីខ្លះដែរទាក់ទងជាមួយនិងយាយតារបស់យាយ? យាយកើតទាក់ពួកគាត់ទេ?

ខ៖ ខ្ញុំកើតទាន់យាយតែតាគាត់ស្លាប់ហើយខ្ញុំកើតអត់ទាន់ទេ បើយាយទាន់ទៅគាត់នេ ដេកចឹងទៅគាត់ងងឹត ដល់ងងឹតទៅនៅតែមួយកន្លែងទៅក៏យកបាយសម្លរទៅជូនយាយទៅក៏លើកបញ្ចុកយាយ ចាសគាត់ងងឹត។

ក៖ ចឹងមានន័យថាកាលយាយនៅក្មេងយាយរបស់យាយគាត់ឡើងចាស់ហើយ?

ខ៖ ចាស គាត់ចាស់ហើយ កាលណឹងគាត់ងងឹតហើយមើលអីអត់ឃើញផង។

កៈ ចុះយាយខាងឪពុកគាត់របស់យាយមានឈ្មោះអ្វីដែរ?

ខៈ អត់ អត់ស្គាល់ទេ ស្គាល់តែតាឈ្មោះមុំយាយអត់ស្គាល់យាយស្លាប់បាត់ទៅហើយ។

កៈ ចឹងមានន័យថានៅពេលដែលយាយកើតមកយាយស្លាប់បានទៅហើយនៅតែតាខាងឪពុក?

ខៈ ចាស គាត់ឈ្មោះតាមុំ។

កៈ ចុះគាត់មានស្រុកកំណើតនៅឯណាដែរយាយ?

ខៈ គាត់នៅស្រុកណឹងដែរ នៅស្រុកណឹងទាំងអស់។

កៈ ចុះយាយមានចាំសាច់រឿងអ្វីខ្លះដែលទាក់ទងជាមួយលោកតាមុំទេ?

ខៈ មានអីពេលដែលគាត់នេះទៅកូនចៅខ្ញុំអ្នករត់យកបាយ តែម៉ែខ្ញុំដាំបាយឆ្អិនអីឆ្អិនទៅមើលមីង៉ាយកបាយទៅឲ្យតា ទៅក៏យកបាយសម្លរទៅជូនតា ចាសយកទៅឲ្យតា គាក៏នៅតូបមួយម្នាក់គាត់ គាត់រៀនធម៌រៀនអាទៅក៏គាត់ណឹងទៅក៏គាត់បង្រៀនកូនក្មេង គាត់បង្រៀនអក្សរកូនក្មេងទៅក៏យកបាយទៅ។

កៈ ខ្ញុំចង់សួរថាតើយាយរស់នៅខេត្តសៀមរាបនេះអត់រយៈពេលប៉ុន្មានឆ្នាំហើយយាយ?

ខៈ ខ្ញុំមកនៅនេះ២៥ឆ្នាំ ៣០ឆ្នាំហើយដឹង ខ្ញុំមកតាំងពីឆ្នាំ៨០ប៉ុន្មានទេកូន។

កៈ ចឹងខ្ញុំចង់សួរថាហេតុអ្វីបានជាយាយផ្លាស់ប្តូរពីខេត្តកណ្តាលមកនៅខេត្តសៀមរាបដែរយាយ?

ខៈ ខ្ញុំមកដំបូងនេះ ដែរយើងមករកស៊ីនេះមកតាមប្តី ប្តីខ្ញុំមកយកនៅសៀមរាប ដល់មកទៅគេយកប្តីទៅបាត់ទៅនៅខ្ញុំ នៅខ្ញុំទៅខ្ញុំរកកន្លែងទៅភ្នំពេញវិញអត់បានខ្ញុំអត់ស្គាល់អត់មានឡានមានអីជិះ ខ្ញុំមិនដឹងទៅឯណាមកឯណាខ្ញុំក៏នៅនេះទៅ ចាសខ្ញុំនៅនេះទៅខ្ញុំនៅវត្តស្វាយ នៅវត្តស្វាយទៅដល់នៅវត្តស្វាយទៅដល់យូរៗទៅកូនខ្ញុំនេះធំទៅគេមានប្រពន្ធមកនៅទន្លេនេះគេយកមកនៅទន្លេ ចាសមកនៅទន្លេនេះទៅមិនដឹងរកស៊ីអី២នាក់កូនពៅណឹងក៏លក់ដូរ លក់ដូរទៅកូនខ្ញុំរៀនអ៊ុំទូកក៏អ៊ុំវេរលិចវេរងកើត វេរលិចវេរងកើតទម្រាំបានលក់ឲ្យគេ ដល់ចេះអ៊ុំទៅជីវភាពណឹងអ៊ុំទូកលក់ទៅលក់ដល់សព្វថ្ងៃនេះឯងឥឡូវនេះលែងអ៊ុំហើយលក់នៅផ្ទះ ដល់ផ្ទះ

នេះលក់អត់ដាច់ឥឡូវនេះគេឲ្យទៅលក់នៅសាលារៀនស្ពីជាស៊ីម ចាសសុំគេជួលដីគេណោះឯងគេជួលឲ្យគេថាសុំជួលដីនេះឲ្យប្អូនមុំនេះបើគ្នាទាល់ណាស់ព្រោះម៉ែគ្នាចាស់ គ្នាទាល់ណាស់សឹងអត់អង្ករស៊ីហើយរួចហើយមិនឲ្យគ្នាលក់ផង គេយកម្នាក់៥០ដុល្លារ ហើយសុំតែ៣០ដុល្លារបានហើយ ចាសដល់ណឹងគេតមកទៀតនាងណឹងជួលពីគ្រូមក មកជួលឲ្យកូនខ្ញុំទៀតដល់ឥឡូវនេះស្អែកនេះគ្រូៗនេះគេថាជួលគេប៉ុន្មាននេះ គេប្រជុំស្អែកគេឲ្យសំបុត្រកូនខ្ញុំនេះប្រជុំទៅថាត្រូវចេញឲ្យគេប៉ុន្មានអីប៉ុន្មាន ចាំគេជួលឲ្យវិញគេអាណិតកូនខ្ញុំថាម្ដាយចាស់ចាសកំសត់ណាស់។

កៈ ចុះយាយមានបងប្អូន ឬសាច់ញាតិដែលរស់នៅក្រៅប្រទេសទេយាយ?

ខៈ ខ្ញុំអត់មានទេ ចាសបាត់អស់រលីងអត់មានខ្ញុំបាត់ប្អូនជីដូនមួយដែលបួស បួសទៅគេថាឲ្យទៅសៀម ថាបើចង់ទៅនែបើលោកប្អូនចង់ទៅស្រុកបារាំងប្អូនគេឲ្យយើងដោះអាវធំចេញណឹងឲ្យសឹក ដល់ចឹងបាត់ប្អូនៅស្រុកគេចឹងទៅ បាត់ដល់សព្វថ្ងៃអត់ឃើញ ចាសបាត់អស់ឈឹង

កៈ ចុះស្វាមីរបស់យាយគាត់មានឈ្មោះអ្វីដែរយាយ?

ខៈ ឈ្មោះប្រុក គឹមប្រុក។

កៈ ចុះយាយបានរៀបអាពាហណ៍ពិពាហណ៍ជាមួយស្វាមីនៅឆ្នាំណាដែរយាយ? ហើយនៅកន្លែងណាដែរយាយ?

ខៈ ខ្ញុំរៀបនៅស្រុកកំរៃងណឹងដែរ ចាសខេត្តកណ្តាលណឹងដែរ ខ្ញុំរៀបពីខ្ញុំអាយុ ១៧ឆ្នាំមិនដឹងឆ្នាអីទេភ្លេចអស់ហើយ ភ្លេចហើយក្បួយអត់ចាំទេ។

កៈ ចឹងយាយរៀបអាពាហណ៍ពិពាហណ៍ណឹងរៀបចំដោយឪពុកម្តាយឬដោយចិត្តខ្លួនឯងដែរ?

ខៈ អត់ទេឪពុកម្តាយខាងប្រុសមកដណ្តឹង មកដណ្តឹងអីទៅក៏យើងបង្គាប់គេទៅការការធំដុំទៅ។

កៈ តើយាយបានទទួលថ្លៃជំនូនពីស្វាមីរបស់យាយទេ?

ខៈ ៣០០០រៀល។

កៈ ចឹងសូមយាយប្រាប់ពីពេលវេលាដំបូងដែលយាយជួបស្វាមីយាយ យាយជួបនៅឯណាដែរយាយ?

ខៈ មកដល់ដណ្ដឹងដល់ផ្ទះអត់មានជួបគ្នាទេ។

កៈ ចុះយាយអត់មានស្គាល់គាត់ពីមុនទេ?

ខៈ អត់ អត់ដែលស្គាល់គេណឹងគេបួសនៅវត្តបរទុមតើគេធ្វើសង្គ្រាជនៅវត្តបរទុម ដល់គេសឹងមកទៅម្ដាយគេណឹងឪពុកគេណឹងទៅឃើញខ្ញុំនៅនឹងផ្ទះស្រុកខ្ញុំណឹងឯង ទៅក៏សួរថាកូនល្បងឯងថាកូនខ្ញុំមានកូនក្រមុំហើយ ដល់នេះទៅគេដឹងទៅកូនគេសឹងមកទៅគេមកដណ្ដឹង។

កៈ ចឹងអត់ដែលស្គាល់គ្នាពីមុនសោះ?

ខៈ អត់ អត់ដែលស្គាល់និយាយពីខ្លាចគ្នាខ្ញុំខ្លាចមែនណឹងការហើយនៅខ្លាចនៅក្មេងប៉ុន្តែប្ដីខ្ញុំគេបួសទៅគេដឹងគេចាស់ទុំ។

កៈ អញ្ចឹងឃើញថាយាយអត់មានជម្រើសខ្លួនឯងទេ?

ខៈ អត់ អត់ទេ អត់ដែលមាននិយាយលេងគ្នាណាអត់ណឹងហើយគេមកដណ្ដឹង។

កៈ ចុះយាយចេះអាន និង ចេះសរសេរអក្សរខ្មែរទេយាយ?

ខៈ អត់សួរចេះទេខ្ញុំកាលនោះអត់បានរៀនផង អត់មានសាលាសាអីរៀនទេកាលពីដើមចាស អត់ស្រុកខ្ញុំអត់ទៅអត់មានរៀនទេបានខ្ញុំអត់ចេះ។

កៈ អញ្ចឹងយាយអត់បានចូលរៀនទេ?

ខៈ ចាស អត់បានរៀនទេចុះគេអាពតទៅមានទៅបានរៀនបានសូត្រអី ពុងអត់ទៅនេះការទៅក៏ហីទៅ

កៈ ចុះយាយមានចេះភាសាអ្វីផ្សេងក្រៅពីភាសាខ្មែរយើងទេ? មានចេះភាសាបារាំងអត់យាយ?

ខៈ អត់ទេ អត់សោះ អត់ទាំងអស់ អត់ចេះទាំងអស់ កាលអាពតនោះអត់មានទេ ទៅបានប្ដីទៅប្ដីយកមកនៅភ្នំពេញទៅក៏មិនបានរៀនបានសូត្រ មកភ្នំពេញហើយបានមួយខែប្ដីគេឡើងទៅ

រៀននៅកំពង់ឆ្នាំងតាមគេទៅរៀននៅកំពង់ឆ្នាំង ទៅគេទៅរៀនទៅសូត្របំពេញវិជ្ជាគេនៅកំពង់ឆ្នាំងអត់បានរៀនបានសូត្រទេ។

ក៖ ចុះយាយមានមិត្តភក្តិស្និតស្នាលដែលធំធាត់មកជាមួយគ្នាទេយាយ?

ខ៖ អត់ដែលខ្ញុំអត់ដែលមានមិត្តភិក្ត កូនអ្នកស្រែដែលមាន កូនអ្នកស្រែដែលមានមិត្តភក្តិទេបើថានេះក៏បបួលគ្នាតោះទៅស្ទឹងទៅមុជទឹកមុជអីក៏ទៅៗ ចាសអត់មានមិនដែលមានមិត្តភក្តិអីផង។

ក៖ ចុះយាយធ្លាប់ធ្វើស្រែចំការទេយាយ?

ខ៖ ខ្ញុំធ្វើស្ទូងអីចឹងទៅ ដល់ស្ទូងស្រែស្ទូងអីស្ទូង ចាសធ្វើ។

ក៖ ចុះអ្វីទៅដែលជាផលវិបាកក្នុងការធ្វើស្រែដែរយាយ?

ខ៖ យើងដូចថាគេភ្ជួរចេះទៅ យើដកសំណាបមុនដំបូងយើងដកសំណាប ដកទៅគេទុក២យប់ចេះទៅ ដល់គេភ្ជួរចេះទៅយើងទៅស្ទូងយើងប្រើដៃនេះ ម្តងដូចថាក្មួយឯងខាងនេះទៅន្មាន៣០នាក់ទៅ ស្អែកខ្ញុំទៅ៣០នាក់ទៀតទៅ លើកដៃគ្នាជួយគ្នាម្នាក់ម្តងចឹងឯងអ្នកស្រែ។

ក៖ ចុះយាយធ្លាប់ប្រកបមុខរបរលក្ខណៈគ្រួសារទេយាយ? ដូចជាចិញ្ចឹមគោ ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់អីទេយាយ?

ខ៖ ខ្ញុំអត់ដែលចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ទេ អត់បានគ្រួសារមកអត់ដែល គឺថាមានតែដាំដំណាំដូចថាដាំស្ពៃ ដាំបន្លែបន្លុកលក់ដូរបន្តិចបន្តួចអី។

ក៖ តាំងពីក្មេងមកដល់ឥឡូវយាយធ្លាប់ប្រកបមុខរបរអ្វីដែរដើម្បីរកប្រាក់ចិញ្ចឹមជីវិតយាយ?

ខ៖ ពីនេះមកខ្ញុំលក់ដូរជាមួយកូននោះឯង ដាក់ឥវ៉ានលក់ចាប់ហួយចាប់អីទៅកូនដល់កូនអ៊ុំទូកទៅខ្ញុំលក់ខ្ទឹម ម្រេច ស្លារ ម្លូរអីចឹងទៅ ចាសដល់លក់ចឹងរហូតដល់ខ្ញុំចូលសីលទៅកូនលែងឲ្យលក់ទៅវាលែងអ៊ុំទូកទៅវាលក់ខ្លួនវា ដល់តែកូនខ្ញុំឈឺកូនខ្ញុំឈឺទៅសន្លប់ទៅ អស់លុយអស់កាក់ទៅនេះឯងខ្ញុំក៏ឈឺវាក៏ឈឺទៅម្តងម្នាក់សន្លប់មួយខែនោះ៣ដងហើយ ចាសកូនខ្ញុំសន្លប់មួយខែ៣ដងហៅគេហៅឯងទៅខ្ញុំលក់អស់ អត់អាណូតអានាមហើយអស់មានលុយមានកាក់អីទៀតហើយ អាលុយ៤០០០ ៥០០០ ទុកធ្វើផ្ទះក៏អស់អីក៏អស់អស់រលីង សព្វថ្ងៃក៏

ទាល់រកតែមួយរៀលដាក់ហោប៉ៅគ្មានចាសទាល់មែន សព្វថ្ងៃកូននោះក៏ខំគេឲ្យទៅលក់ឯនោះទៅគ្រាន់ទិញអង្ករហូបទៅក្មួយ ក្រមែនអត់ក្រទេទាល់ម៉ង រស់ដោយសារគេព្រឹកមិញឃើញគេយកអង្ករមកឲ្យ៥គីឡូខ្ញុំបានដាំទៀតហើយ កំសត់ណាស់ខ្ញុំ។

ក៖ ចឹងខ្ញុំសុំឲ្យយាយជួយរៀបរាប់អំពីបទពិសោធន៍របស់យាយកាលពីសម័យប៉ុល ពតតិចមកយាយ យាយអាចប្រាប់ថាយាយមានអ្វីកើតឡើងខ្លះ យាយជួបបទពិសោធន៍អ្វីខ្លះសម័យប៉ុល ពតណា?

ខ៖ ចាស សម័យប៉ុល ពតនេះកំសត់មែន លីថាកន្ទៀតទៅស្ងួងទៅអីចេះទៅ កន្ទៀតខ្ទមដាក់បាយក្នុងខ្ទមទៅដូចថាមានលុយកាក់តិចតួចទៅដាក់ក្នុងខ្ទមទៅធ្វើទូលធ្វើអីទៅខ្លាចគេយកទៅធ្វើទូលធ្វើធូន់ធ្វើអីទៅកុំឲ្យវាដឹង ហើយបើមានអង្ករមានអីណឹងយកទៅច្រកនៅក្រោមកន្ទេលដេក ចាសដាក់ដូចថាកន្ទេលយើងវាជាន់ហើយដាក់អង្ករពីលើទៅក៏ដេកពីលើមានកម្សត់ចឹងទៀត ហើយដាំបាយម្ដាយខ្ញុំអើយដាំបាយយកខ្លាចអាណិតដើមឈើដែលដាំថ្នាំផឹកយកទៅដាក់ពីលើណឹងឯងគេថា ដាំទឹកអីល្អក់ៗចេះទៅគេមើលឃើញបាយទៅគេធ្វើទុក្ខម៉ែខ្ញុំចាសយកកម្មយកពារម៉ែខ្ញុំណាស់ហើយខ្ញុំមិនដឹងធ្វើម៉េចទេកម្សត់ព្រោះអត់ហើយខ្ញុំងាប់អស់កូន២ទៀត ចាសអត់មានបាយឲ្យកូនហូប កូននោះក៏លោតអណ្ដូងតែអណ្ដូងនោះវាប្រហែល៣ម៉ែត្រ កូនខ្ញុំវាឃើញកង្កែបទៅវាលោតទៅចាប់ ស៊ីកង្កែបទាំងរស់ចាសក៏ឡើងអត់រួចក៏ហៅគេអ្នកស្រុកមកគេជួយយកកូនណឹងមក កូនណឹងបានតែប៉ុន្មានក៏ងាប់ ងាប់កូនអត់២នាក់ខ្ញុំទៅក៏នៅសល់តែកូន៤នាក់ ចាសកម្សត់មែន ហើយដល់នេះទៅកូនដើរលក់ដូរក្មួយអើយ ខ្ញុំធ្វើអាកោរឲ្យកូនដើរលក់ដើរដូរគ្រាន់តែចិញ្ចឹមខ្លួន ចិញ្ចឹមដល់កូនបានប្ដីបានប្រពន្ធគ្រប់គ្នា។

ក៖ ចុះកាលសម័យប៉ុល ពតណឹងយាយនៅឯណាដែរយាយ?

ខ៖ ខ្ញុំកាលប៉ុល ពតណឹងខ្ញុំនៅនឹងស្អីគេហៅស្រុកអីគេខ្ញុំនៅ។

ក៖ នៅខេត្តណាដែរយាយចឹង?

ខ៖ នៅក្នុងស្រុកឃុំនោះឯង នៅឃ្លោកំប៉ុត ភូមិបាឡាំង។

ក៖ ខេត្តណាដែរយាយ?

ខ៖ នៅភូមិបាឡាំង នៅសង្កាត់ភ្នំពេញ នៅភូមិបាឡាំងនេះឯងខ្ញុំនៅ ភ្លេចហើយ។ នៅនោះទៅក៏ដើរធ្វើលក់ដូរធ្វើអាកោរឲ្យកូនលក់ទៅសព្វគ្រប់ទៅបានអង្ករស៊ីអីស៊ីទៅ ហើយកូនមួយតូច

នោះមីមួយតូចនោះក៏អាមួយនោះក៏ឃ្វាលគោឲ្យគេទៅគេឲ្យអង្ករឲ្យបាយហូបទៅ វេទនាណាស់ខ្ញុំ កម្សត់មែនខ្ញុំយំរាល់ថ្ងៃដែលអត់បាយ ហើយខ្ញុំហើម ក្បាលជង្គង់នេះអត់មានទៅណារួចហើមជើង ហើមកំភ្លៅ អត់ទៅណារួចទេតែកូនណឹងដើរសុំគេទៅគេញាតិអ្នកស្រុកណឹងគេឲ្យបាយឲ្យអីស៊ីទៅកូននោះឃ្វាលគោគេ គេឲ្យមួយដុំ មួយដុំមកទៅហូប វេទនាណាស់ក្មួយអើយកាលនៅបាឡាំង មិនដឹងជាសង្កាត់អីនៅភូមិបាឡាំង។

ក៖ ចុះកាលសម័យប៉ុល ពតណឹងគេប្រើយាយឲ្យធ្វើអ្វីខ្លះដែរយាយ?

ខ៖ គេឲ្យខ្ញុំនេះ មុនដំបូងគេឲ្យរែងអង្ករ គេឲ្យរែងអង្ករគេសួរថាអ្នកណាចេះរែង ខ្ញុំថាខ្ញុំចេះរែងចេះអុំ គេថាឲ្យរែងទៅចឹងអុំមានគេអុំហើយគេឲ្យរែងអង្ករដល់រែងអង្ករចឹងទៅគេដាំបាយឲ្យស៊ីស៊ីទៅក៏អ្នកស្រុកណឹងចិត្តល្អដែរគេល្ងាចឡើងគេដាក់អង្ករមកប៉ុននេះមកឲ្យកូនស៊ី នៃគេស្លឹកចេកដាក់ពីលើទៅគេឲ្យកូនកញ្ជើរមួយទៅក៏គេដាក់ស្លឹកចេកពីលើគេដាក់អង្កាម មកដល់នេះយកអង្កាមចេញទៅយកអង្ករនេះដាំបបរឲ្យកូនហូប ថាខ្ញុំកម្សត់មែន ដល់នេះទៅខ្ញុំរួចពីអង្ករទៅគេឲ្យទៅស្ទូងទៅដកសំណាប គេឲ្យទៅដកសំណាបព្រះអង្គអើយខ្ញុំដកអត់បាន ចុះខ្ញុំវាទ្រោមចុះខ្ញុំដែលអត់បាយទៅវាស្គមទៅដកអត់បានទៅគេចិត្តល្អដែរអ្នកស្រុកនោះឯង មិត្តឯងដកបានន្ទានខ្ញុំថាខ្ញុំដកបានសំណាប ៣ដំបរគេឲ្យដកន្ទានផ្លូត ៥ផ្លូត ទើបតែបាន៣ដំបរគាត់ដើររាប់គេអស់គ្រប់គ្នាទៅក៏ទាញបស់គេមកដាក់ឲ្យខ្ញុំឲ្យបាន៥ផ្លូតដូចគេថាគ្រប់អស់ហើយប្រាប់មេៗ បានអ្នកស្រុកគេអាណិតខ្ញុំជួយគេស្រណោះខ្ញុំពេកខ្ញុំស្គម ស្គមជាងនេះទៀតជាងសព្វថ្ងៃទៀតក៏ចុះទៅបានគេអាណិតទៅបានខ្ញុំរស់តាមណឹងឯង រួចដល់ល្ងាចឡើងទៅ ពេលមកពីស្ទូងពីអីចឹងទៅមកពីដកសំណាបទៅគេវិចបាយឲ្យទៅក៏ដាក់ក្នុងថ្នក់យកមកឲ្យកូនចិញ្ចឹមមីកូនពៅដែលនៅសព្វថ្ងៃ អួយខ្ញុំកម្សត់មែនខ្ញុំយំរាល់ថ្ងៃហើយកូនខ្ញុំទាររតែបាយញុំបាយ បាយ។

ក៖ អញ្ចឹងខ្ញុំចង់សួរយាយថាតើក្នុងជីវិរបស់យាយពេលវេលាណាដែលយាយគិតថាជាពេលវេលាពិបាកជាងគេក្នុងជីវិតរបស់យាយ? ពេលណាដែរ?

ខ៖ ពេលដែលខ្ញុំពិបាក ពិបាកអាពេលនោះឯងពេលអត់ពិបាកនៅសម័យប៉ុលពតដល់ខ្ញុំរួចពីពិបាកទៅខ្ញុំមកចុងឃ្មៀសនេះកូននេះគេរត់មកនេះមានអាមួយនោះធំក៏យកវាមក មកទៅវាយកខ្ញុំមក មកទៅមីកូនពៅខ្ញុំនោះវានៅតូច ដល់នៅតូចមិនដឹងរកស៊ីអីទេហា ទៅខ្ញុំចៀនអានំជើងជ្រូកដែលគេដាក់ចេះនោះ ក៏កិនម្សៅធ្វើនំជើងជ្រូកណឹងលក់ទៅ លក់នំណឹងទៅកូនខ្ញុំនោះគេមីកូនពៅនោះគេថាចឹងខ្ញុំគិតរកទៅលក់នៅអុំទូកចេះឯង ខ្ញុំលក់នំណឹងឯងជើងជ្រូក

ទៅបានបង្ករលក់ចាប់ហួយតិចៗ ទៅចាប់ហួយតិចៗមកទៅក៏លក់ខ្ចឹម ម្រេចចឹងទៅ ទឹកត្រី ទឹកស៊ីអ៊ីវចឹងទៅបន្តិច បន្តិចទៅក៏បានរស់ចឹងទៅក៏បានកើតជាធំដុំទៅក៏បានជីវភាពណឹងរស់បានចាសបានទល់សព្វថ្ងៃដល់មកសព្វថ្ងៃនេះដល់មកកូនធំទៅកូនធ្លាប់ខ្លួនឈឺ៣ឆ្នាំនេះ សន្លប់ក្នុងមួយខែ៣ដង សន្លប់ម្តង៧ដងប្រហែលខ្ញុំអង្គុយនេះ៧ដងហើយ ចាសបាត់ឈឹង ឈឹងទៅហៅតែគេទៅចាស ទៅក៏អស់ខ្លួននិងកូនណឹងទៀតទៅពេទ្យទៅអីទៅអស់លុយអស់កាក់ លុយកាក់ក៏បោសអស់ហើយមានប្រាក់ទាំងប៉ុន្មានអស់ហើយ អស់រលីងដល់សព្វថ្ងៃទាល់មែនទែន។

ក៖ ចុះពេលវេលាណាដែលយាយគិតថាជាពេលវេលាដែលយាយសប្បាយចិត្តជាងគេក្នុងជីវិត? មិញនិយាយពីពិបាកចុះយាយសប្បាយចិត្តជាងគេនៅពេលដែរយាយ?

ខ៖ មិនដឹងពេលណាបានសប្បាយទេនេះមានទាន់សប្បាយទេ អត់ទាន់សប្បាយអត់ទាន់មានលុយមានកាក់អត់ទាន់សប្បាយកំពុងតែជំពាក់គេ កំពុងតែជំពាក់គេអង្គការគេ យកលុយអង្គការយកអីនោះ។

ក៖ តាំងពីក្មេងមកតើយាយមានក្តីស្រម៉ៃចង់ធ្វើអ្វីទេពេលធំឡើងយាយ?

ខ៖ អេខ្ញុំពីក្មេងមិញយាយខ្ញុំឲ្យត្បាញខ្ញុំអត់ត្បាញទេខ្ញុំធ្វើលោកស្រីម៉ែខ្ញុំឲ្យខ្ញុំត្បាញមីង៉ាកូនកីមានស្ពឺមានកីមានទាំងអស់សូត្រមានទាំងអស់ អូ!មិនត្បាញទេខ្ញុំធ្វើលោកស្រី អត់ត្បាញ អត់រៀន អត់ធ្វើទេយាយតាខ្ញុំត្បាញសារ៉ុងត្បាញហូលផាម៉ូងចែកតែកូនចៅគាត់ស្លៀកពាក់ ខ្ញុំមិនរៀនសោះខ្ញុំថាធ្វើលោកស្រីចេញតែលោកស្រី ណឹងហើយខ្ញុំអត់រៀនមែន ខ្ញុំដើរតែលេងសប្បាយ ខ្ញុំរត់តែលេងសប្បាយ។

ក៖ តើយាយចូលចិត្តពិសារម្ហូបអ្វីជាងគេដែរយាយ?

ខ៖ ទេសព្វថ្ងៃក្មួយអើយមានម្ហូបអីបើជូនណាយើងមានសម្លរម្ជូរអីទៅកូនត្រីអីទៅណឹងចូលចិត្តកូនត្រីតូចៗណឹងឯងអូយឆ្ងាញ់ណាស់ សម្លរម្ជូរប្រាច់អីណឹងប៉ុណ្ណឹងឯងសព្វថ្ងៃនោះ។

ក៖ ចុះយាយចូលចិត្តស្តាប់បទចម្រៀងទេយាយ?

ខ៖ មិនសូវប៉ុនទេ បើស្តាប់លោកទេសលោកអីចូលចិត្ត។

ក៖ ចុះពីក្មេងមកចូលចិត្តស្តាប់ទេ?

ខ៖ អូយកាលណឹងចូលចិត្តនិយាយពីបទចម្រៀងពីដើមមិញ។

ក៖ តាំងពីដើមមកចូលចិត្តស្ដាប់បទអ្វីដែរយាយ?

ខ៖ ពីដើមមិញស៊ិន ស៊ីសាមុតនោះឯងចូលចិត្តណាស់។

ក៖ ចុះបទណាយាយចូលចិត្តជាងគេដែរ?

ខ៖ មិនដឹងបទអីទេខ្ញុំភ្លេចអស់ហើយសព្វថ្ងៃ ភ្លេចអស់ហើយសព្វថ្ងៃគិតតែពីធម៌ម្ដង។

ក៖ ចុះយាយចេះលេងឧបករណ៍តន្ត្រីអីទេយាយ?

ខ៖ មិនដែលទេ អត់ចេះទេមានតែលេងបិទពួន មានលេងចាប់កូនខ្លែងតែប៉ុណ្ណឹងឯង។

ក៖ ចុះនៅក្នុងក្រុមគ្រួសារយាយមាននរណាចេះលេងភ្លេងទេយាយ?

ខ៖ អត់ទេ អត់មាន

ក៖ តាំងពីក្មេងមកយាយចូលចិត្តលេងល្បែងប្រជាប្រិយណាជាងគេ?

ខ៖ ចាស ចាប់កូនខ្លែង លាក់កន្សែងប៉ុណ្ណោះឯង។

ក៖ ចុះចោលឈូងអី?

ខ៖ ចាសចោលឈូង ចោលអីនោះឯងទៅមកជួសគ្នានោះឯង ប៉ុណ្ណោះឯង។

ក៖ អញ្ចឹងជិតមកដល់ចុងបញ្ចប់នេះ តើយាយមានអ្វីចង់ផ្ដាំផ្ញើរទៅកាន់កូនចៅជំនាន់ក្រោយរបស់យាយទេយាយ?

ខ៖ ឲ្យកូនចៅជំនាន់ក្រោយណឹងឲ្យវាកុំឲ្យដូចខ្ញុំទៀត ឲ្យគេរកស៊ីមានបានដូចសម័យគេសព្វថ្ងៃទៅ ខ្ញុំនេះវាពិបាកខ្លាំងណាស់កម្សត់ហើយទាល់ទៀត ណឹងហើយឲ្យគេរកស៊ីមានបានទៅឲ្យត្រជាក់ត្រជុំទៅ ទេវតាជួយថែរក្សាអាយុវែង។

ក៖ យាយមានអ្វីចង់ផ្ដាំផ្ញើរទៀតទេយាយ?

ខ៖ ចាសមានតែប៉ុណ្ណឹងឯង។

ក៖ បាទអញ្ចឹងខ្ញុំសូមអរគុណយាយដែលបានអនុញ្ញាតឲ្យខ្ញុំសម្ភាសន៍ ដែលបានចំណាយពេលសម្ភាសន៍ជាមួយខ្ញុំ ហើយខ្ញុំសូមជូនពរឲ្យយាយមានសុខភាព និងមានសុភមង្គលណាយាយ។

ខ៖ សាធុ សាធុ។

ក៖ បាទ បាទ៕